47

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
***********

សាលាដំបូងរាជធានីភ្នំពេញ
*******

សាលក្រមព្រហ្មទណ្ឌលេខ: ៦៩៣ "ក្រ២ វ"
ចុះថ្ងៃទី ២៤.០៦.២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦៨៨
ចុះថ្ងៃទី ១២.១២.២០១៩
ស៊ើបសួរលេខ: ៥៩២៦
ចុះថ្ងៃទី ១៤.១២.២០១៩
ជំនុំជម្រះលេខ: ១៥៣០
ចុះថ្ងៃទី ០៣.០៤.២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជំនុំជម្រះជាសាធារណ: នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០២ និង ៣០ នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រីចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកស្រីអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា

-លោកស្រីចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-កញ្ញា [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦៨៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ខា ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបររត់ម៉ូតូឌុប សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០១នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤៧៦៣ "ភ" ដ.ឃ.ដ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩។(ម១)

២-ឈ្មោះ [redacted] ផែហ្វូត ហៅ សិលា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" កូនគ្មាន ទោសពីមុនគ្មាន ជាទីតិជន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៤៧៦២ "ភ" ដ.ឃ.ដ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩។(ម១)

-មានលោក [redacted] ឡុងឌី អត្តលេខ ១១២៨ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរនាក់ ដែលមានការិយាល័យនៅផ្ទះលេខ០០២ ផ្លូវលេខ២០២ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល។

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ហ្វ្រើន បន្ទប់លេខ៣០៥ ផ្លូវលេខ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ១៧ និង ៣០នាទី ចំណុចផ្ទះសំណាក់ប្រ៊ីន បន្ទប់លេខ៣០៥ បណ្ដោយផ្លូវលេខ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចនគរបាលការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀនឆ្លងដែននៃមន្ទីរប្រឆាំងគ្រឿងញៀនបានបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយបានឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ដែលមានឈ្មោះ [redacted] ខ្លា ភេទប្រុស និងឈ្មោះ [redacted] ឆែហួត ហៅ សិលា ភេទប្រុស ដោយឆែកឃើញមានក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ដែលមានទម្ងន់ ៣៣.៨៧ក្រាម។ ថ្នាំញៀននេះជារបស់ឈ្មោះ ម៉ាប់ ភេទប្រុស ដែលបានប្រើឈ្មោះ [redacted] ខ្លា និងឈ្មោះ [redacted] ឆែហួត យកថ្នាំញៀននេះទៅឱ្យម៉ូយដោយទទួលប្រាក់ចំនួន ៦០០$ ហើយឈ្មោះ ម៉ាប់ បានផ្ដល់ឈ្នួលក្នុងម្នាក់ចំនួន ២០$ តែក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនបាន និងដកហូតបានថ្នាំញៀនខាងលើរួចកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្ដង។

-បានឃើញ: របាយការណ៍សំយោគលេខ ៤៤២៧ រ.ប.ក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។

-បានឃើញ: ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៥៩៥០ អ.យ.ខ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៣១ អ.យ.ប ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ: ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៩៥ "ខ" ដ.ជ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ: ដីកាសម្រេចលើកលែងចោទប្រកាន់លេខ ១៦២៤ "ខ" ដ.ជ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ខ្លា បានឆ្លើយថា: កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ១៧ និង៣០នាទី ខ្លួនទទួលយកថ្នាំញៀនពីឈ្មោះ [redacted] ឆែហួត ភេទប្រុស រួចយកឡើងទៅប្រគល់ឱ្យអ្នកគេបញ្ជាទិញក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន និងឈ្មោះ [redacted] ឆែហួត និងបានដកហូតបានថ្នាំញៀនចំនួនមួយកញ្ចប់។ មុនដំបូងគេទូរស័ព្ទទិញថ្នាំញៀនពីឈ្មោះ ម៉ាប់ ហើយឈ្មោះ ម៉ាប់ បានប្រើខ្លួនឱ្យទាក់ទងទៅអ្នកទិញដើម្បីយកថ្នាំញៀនឱ្យគេ និងទទួលយកលុយចំនួន ៦០០$ ពីគេ។ ខ្លួនប្រើឱ្យឈ្មោះ [redacted] ឆែហួត វេលុយទៅឱ្យឈ្មោះ ម៉ាប់ និងឱ្យឈ្មោះ [redacted] ឆែហួត យកថ្នាំញៀនពីឈ្មោះ ម៉ាប់ មកឱ្យខ្លួន ហើយខ្លួនបានយកថ្នាំញៀនទៅប្រគល់ឱ្យអ្នកបញ្ជាទិញ តែក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនបានតែម្ដង។ ចំពោះរឿងនេះ ឈ្មោះ ម៉ាប់ បានឱ្យថ្លៃឈ្នួលមកខ្លួន និងឈ្មោះ [redacted] ឆែហួត ម្នាក់១បានចំនួន ២០$ ។

-ជនជាប់ចោទឈ្មោះ [redacted] ឆែហួត ហៅ សិលា បានឆ្លើយថា: កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ ម៉ោងប្រហែល ១ ថ្ងៃត្រង់ ឈ្មោះ [redacted] ខ្លា បានឱ្យខ្លួនយកប្រាក់ចំនួន ៦០០$ វេរលុយឱ្យទៅឈ្មោះ ម៉ាប់ ។ ពេលវេរួចឈ្មោះ ម៉ាប់ បានប្រាប់ឱ្យខ្លួនទៅយកកញ្ចប់ទំពីគាត់យកទៅឱ្យឈ្មោះ [redacted] ខ្លា ដោយខ្លួនពុំដឹងថាជាថ្នាំញៀននោះទេ។ លុះជិះដល់ពាក់កណ្ដាលផ្លូវឈ្មោះ ម៉ាប់ បានទូរស័ព្ទមកប្រាប់ថា ឱ្យប្រយ័ត្នប្រយែងតាមផ្លូវ ទើបខ្លួនដឹងថាកញ្ចប់ទំនោះគឺជាគ្រឿងញៀន។ ពេល

ឈ្មោះ ម៉ាប់ ពិតជារបស់ឈ្មោះ ម៉ាប់ - អ្នកទិញ

នោះខ្លួនបានយកថ្នាំញៀនឱ្យទៅឈ្មោះ [redacted] ខ្លា ទៅផ្ទះសំណាក់ហ្វ្រីន ស្ថិតនៅសង្កាត់ប៉ងព្រលិត ខណ្ឌ៧មករា ស្រាប់តែសមត្ថកិច្ចមកឃាត់ខ្លួនពួកខ្លួនតែម្តង។

-សាក្សីឈ្មោះ ហែន ពិសិដ្ឋ ជាសមត្ថកិច្ចបានឆ្លើយថាៈ នៅថ្ងៃកើតហេតុនោះគឺខ្លួនខ្ញុំជាអ្នកចុះដោយផ្ទាល់ ហើយក៏បានប្រើវិធានញុះញង់ ដើម្បីឈានទៅចាប់ឈ្មោះ [redacted] ខ្លា ។នៅពេលដែលចុះប្រតិបត្តិការគឺសមត្ថកិច្ចបានចំណាយដើម្បីទិញបានគ្រឿងញៀន ហើយលុយគឺត្រូវបានវេទៅឱ្យអ្នកទិញថ្នាំញៀនរួចហើយ។ ម្យ៉ាងទៀតដើម្បីឈានទៅចាប់មេក្លោងដែលជួញគ្រឿងញៀនផងដែរ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ ៣៩៦២ រ.វ.ត ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ក្រឡាបញ្ជីអានលទ្ធផលកោសល្យវិច័យលេខ ២៣៩៦៤/២០ មពអជបគញ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់រួចមកឃើញថាពិតមែនតែជនជាប់ចោទទាំងពីរនាក់បានឆ្លើយដោះសារនាពេលសវនាការគឺអាចសន្និដ្ឋានតាមអង្គហេតុនាថ្ងៃកើតហេតុនោះ សមត្ថកិច្ចបានទំនាក់ទំនងស្វែងរកអ្នកលក់ដូរគ្រឿងញៀន។ បន្ទាប់ពីសមត្ថកិច្ចបានទាក់ទងទៅឈ្មោះ [redacted] ខ្លា រួចហើយក៏ប្រគល់លុយទៅឱ្យ ហើយឈ្មោះ [redacted] ខ្លា ក៏បានទាក់ទងទៅឈ្មោះ [redacted] នៃហួត ដើម្បីវេលុយទៅឱ្យឈ្មោះ ម៉ាប់ ដើម្បីទទួលបានថ្នាំញៀនមកវិញក៏ឈ្មោះ [redacted] ខ្លា ប្រគល់ថ្នាំញៀនទៅឱ្យសមត្ថកិច្ចវិញ។ ផ្អែកតាមអង្គហេតុទាំងអស់នេះឃើញថា អំពើរបស់ជនជាប់ចោទដែលបានទទួលថ្នាំញៀនពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងប្រគល់ពីមនុស្សម្នាក់ទៅឱ្យមនុស្សម្នាក់ទៀតដោយទទួលបានកម្រៃ ថ្វីត្បិតតែជនជាប់ចោទឈ្មោះ [redacted] ខ្លា ថាកម្រៃនោះចែកគ្នា ហើយឈ្មោះ [redacted] នៃហួត ថាបានទទួលកម្រៃចំនួន ៥០$ ។ ទោះបីចម្លើយខុសគ្នាយ៉ាងណាក៏ដោយ តែជនជាប់ចោទទាំងពីរនាក់ពិតជាទទួលកម្រៃពីអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។ ដូចនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីរនាក់ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

-លោក [redacted] ឡុងឌី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរនាក់ បានធ្វើសេចក្តីសន្និដ្ឋានថាៈ តាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់បានឆ្លើយសារភាពថា ពិតជាបានយកថ្នាំញៀនទៅឱ្យឈ្មោះ ម៉ាប់ ប្រាកដមែន។ ប៉ុន្តែបើពិនិត្យទៅលើសកម្មភាពរបស់ជនជាប់ចោទទាំងពីរនាក់វិញគឺពួកគាត់ធ្វើពុំមែនជាលក្ខណៈអាជីពរបស់ពួកគាត់ទេ។ គឺថាដោយសារមានការពឹងពាក់ពីខាងអ្នកទិញ ហើយក៏បានយកទៅឱ្យ។ សកម្មភាពនេះគឺកូនក្តីខ្លួនគ្រាន់តែទទួលកម្រៃជើងសារតែប៉ុណ្ណោះ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ខ្លា ថាៈ ចំពោះរឿងនេះ ខ្លួនស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] នៃហួត ថាៈ ចំពោះរឿងនេះគឺខ្លួនស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ខ្លា និងឈ្មោះ [redacted] នៃហួត/

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗនៅក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលសុំណុំរឿងព្រហ្មទណ្ឌលេខ ៨៦៨៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ មកជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៩៥ "ខ" ដ.ដ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទឈ្មោះ [redacted] ខ្នា ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ផៃហួត ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ហ្គ្រីន បន្ទប់លេខ៣០៥ ផ្លូវលេខ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង ៣០ នាទី នៅចំណុចផ្ទះសំណាក់ហ្គ្រីន បន្ទប់លេខ៣០៥ តាមបណ្ដោយផ្លូវលេខ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចនគរបាលការិយាល័យប្រឆាំងគ្រឿងញៀនឆ្លងដែនបានចុះបង្ក្រាបករណី គ្រឿងញៀន ក៏បានឃាត់ខ្លួនជនសង្ស័យចំនួនពីរនាក់មានឈ្មោះ [redacted] ខ្នា ភេទប្រុស និងឈ្មោះ [redacted] ផៃហួត ភេទប្រុស ដោយដកហូតបានថ្នាំញៀនក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ដែលមានទម្ងន់ ៣៣.៨៧ ក្រាម និងឃាត់ខ្លួនជនល្មើសតែម្ដង។

៣-ជនជាប់ចោទឈ្មោះ [redacted] ខ្នា បានឆ្លើយថា: នៅថ្ងៃកើតហេតុនោះឈ្មោះ ម៉ាប់ បានទូរស័ព្ទមកខ្លួន ហើយខ្លួនបានហៅឈ្មោះ [redacted] ផៃហួត យកថ្នាំញៀនទៅឱ្យគេចំនួន០១កញ្ចប់ និងទទួលលុយពីគេមកវិញចំនួន ៦០០$ ដោយឈ្មោះ ម៉ាប់ ឱ្យថ្លៃឈ្នួលពួកខ្លួនម្នាក់ៗចំនួន ២០$ ប៉ុន្តែពេលមកដល់ពាក់កណ្ដាលផ្លូវក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្ដង។

៤-ជនជាប់ចោទឈ្មោះ [redacted] ផៃហួត បានឆ្លើយថា: នៅថ្ងៃកើតហេតុឈ្មោះ [redacted] ខ្នា បានឱ្យខ្លួនយកប្រាក់ចំនួន ៦០០$ វេទៅឱ្យឈ្មោះ ម៉ាប់ ពេលវេរួចឈ្មោះ ម៉ាប់ បានប្រាប់ឱ្យខ្លួនទៅយកកញ្ចប់ទំពីគាត់យកទៅឱ្យឈ្មោះ [redacted] ខ្នា នៅផ្ទះសំណាក់ហ្គ្រីន ស្ថិតនៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

៥-ផ្អែកតាមរបាយការណ៍សរុបលេខ ៤៤២៧ រ.ប.ក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា ឈ្មោះ [redacted] ខ្នា ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះ [redacted] ផៃហួត ភេទប្រុស អាយុ២១ឆ្នាំ ពិតជាបានប្រព្រឹត្តនូវសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលសមត្ថកិច្ចធ្វើការឃាត់ខ្លួន កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ នៅចំណុចផ្ទះសំណាក់ហ្គ្រីន បន្ទប់លេខ៣០៥ បណ្ដោយផ្លូវលេខ ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ប្រាកដមែន។

៦-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២៣៤៦៤/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបង្ហាញថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន(ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៧.២១% (ចិតសិបប្រាំពីរ ក្បៀស ម្ភៃមួយ

ភាគរយ) នៃទម្ងន់សរុបរាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-សារធាតុញៀនដែលចាប់យកពីជនជាប់ចោទឈ្មោះ [redacted] ខ្វា និងឈ្មោះ [redacted] ឆៃហួត ជាក្រាមពណ៌សថ្លា មានទម្ងន់សរុបចំនួន ៣៣.៨៧ ក្រាម ដែលជាសារធាតុមេតំហ្វេតាមីនមានកម្រិតភាពសុទ្ធចំនួន ៧៧.២១% នៃទម្ងន់សរុប ដូចនេះបរិមាណសុទ្ធមេតំហ្វេតាមីនគឺ ៧៧.២១ x ៣៣.៨៧ ៖ ១០០ = ២៦.១៥ ក្រាម ឃើញថាសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណភាពសុទ្ធចំនួន ២៦.១៥ (ម្ភៃប្រាំមួយ ក្បៀស ដប់ប្រាំ)ក្រាម ដូចនេះបរិមាណសុទ្ធលើស ១៥ (ក្រាម) គឺស្ថិតនៅក្នុងមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ខ្វា និងឈ្មោះ [redacted] ឆៃហួត ដែលបានយកថ្នាំញៀនទៅឱ្យអ្នកដទៃដោយទទួលបានកម្រៃ នឹងត្រូវបានសមត្ថកិច្ចឆែកឆេរឃើញមានថ្នាំញៀនចំនួនមួយកញ្ចប់ទៅនឹងខ្លួន ត្រូវច្បាប់កំណត់ថាជាបទល្មើស ជួញដូរទុកដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ១០ (ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល តាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ និងសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយល្អក្នុងសង្គម ដែលច្បាប់ហាមឃាត់ជាពិសេសបានបំពានទៅនឹងមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-ជនជាប់ចោទជានីតិជនដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១១-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ខ្វា ភេទប្រុស និងឈ្មោះ [redacted] ឆៃហួត ភេទប្រុស ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំឱ្យតុលាការសម្រេចបន្ធូរបន្ថយទៅលើស្ថានសម្រាលទោសមកលើកូនក្តីខ្លួន គប្បីតុលាការនឹងលើកយកមកពិចារណា។

១៣-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ខ្វា ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឆៃហួត ហៅ សិលា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ហ្គ្រីន បន្ទប់លេខ៣០៥ ផ្លូវលេខ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤-វត្ថុតាងចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៩៦២ រ.វ.គ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាវត្ថុដែលពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺមាន ១-ស្រោមសំបុត្រពណ៌សបិតជិតមានសរសេរថា ម្សៅក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យថាមានតម្រុយជាគ្រឿងញៀនទម្ងន់ ៣៣.៨៧/

ក្រាម ដោយកោទការវត្តុកមេដៃសង្ស័យឈ្មោះ [redacted] ខ្នា និងឈ្មោះ [redacted] ផៃហួត និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ខ្នា ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបររត់ម៉ូតូឌុប សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួលគ្មានលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០១នាក់ ទោសពីមុនគ្មាន ជាទីតិជន។

ដាក់ពន្ធនាគារកំណត់ ៦(ប្រាំមួយ) ឆ្នាំ។

ខ-ឈ្មោះ [redacted] ផៃហួត ហៅ សិលា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" កូនគ្មាន ទោសពីមុនគ្មាន ជាទីតិជន។

ដាក់ពន្ធនាគារកំណត់ ៦(ប្រាំមួយ) ឆ្នាំ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ហ្គ្រីន បន្ទប់លេខ៣០៥ ផ្លូវលេខ ២២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-រឹបអូសវត្ថុតាងមាន: ថ្នាំញៀនចំនួន ៣៣.៨៧ ក្រាម ។

សាលក្រមនេះជំនុំជម្រះជាសាធារណ:នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណ: នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ ខន ខ្នា និងឈ្មោះ ហុង ផៃហួត។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០
ក្រឡាបញ្ជី

[redacted]